## តើវ៉ាក់សាំងកូវីដ-១៩ នឹងចាក់ឱ្យតែក្រុមអាទិភាពទី១ និងទី២ មែនទេ?




ដោយសារការផ្គត់ផ្គង់វ៉ាក់សាំងមានកម្រិត ក្រុមអាទិភាពទាំងពីរបានចាក់វ៉ាក់សាំងមុនគេ។ អង្គការសុខភាពពិភពលោកបានណែនាំអំពីក្រុមអាទិភាពទី១ រួមមានបុគ្គលិកសុខាភិបាល ដើម្បីរក្សាដំណើរការនៃប្រព័ន្ធសុខាភិបាល។ ក្រុមអាទិភាពទី២ មួយចំនួនទៀត រួមមាន មនុស្សចាស់ អ្នកដែលមានជំងឺប្រចាំកាយដែលមានហានិភ័យនៃការឈឺ បន្ទាប់ពីឆ្លងជំងឺកូវីដ-១៩ និងអ្នកដែលមានហានិភ័យក្នុងការប៉ះពាល់ជាមួយវីរុសកូវីដ-១៩។ ប្រសិនបើអ្នកមិនប្រាកដថាអ្នកស្ថិតក្នុងក្រុមមានហានិភ័យខ្ពស់ ឬ ក្រុមអាទិភាព សូមសួរទៅបុគ្គលិកសុខាភិបាល។

**មនុស្សពេញវ័យទាំងអស់នឹងបានចាក់វ៉ាក់សាំងនេះបន្តបន្ទាប់គ្នាផងដែរ**



## តើស្ត្រីមានផ្ទៃពោះនឹងបានចាក់វ៉ាក់សាំងកូវីដ-១៩ នេះដែរ ឬ ទេ?

ដោយសារបច្ចុប្បន្ននេះ មិនមានទិន្នន័យគ្រប់គ្រាន់អំពីសុវត្ថិភាព និងប្រសិទ្ធភាពរបស់វ៉ាក់សាំងកូវីដ-១៩ ចំពោះស្ត្រីមានផ្ទៃពោះ ពួកគេមិនបានណែនាំ ឬចាត់ជាក្រុមអាទិភាពក្នុងការបានចាក់វ៉ាក់សាំងនេះទេ នៅក្នុងពេលនេះ។



## តើខ្ញុំធ្វើម៉េចទើបដឹងថា ត្រូវទៅចាក់វ៉ាក់សាំងនៅកន្លែងណា ពេលណា? ហើយតើវ៉ាក់សាំងកូវីដ-១៩ នឹងចាប់ផ្តើមចាក់នៅពេលណា?

- រាជរដ្ឋាភិបាលកម្ពុជានឹងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធចុះឈ្មោះចាក់វ៉ាក់សាំងតាមអនឡាញ។ យើងនឹងផ្តល់ព័ត៌មានលម្អិត និងសេចក្តីណែនាំក្នុងការចុះឈ្មោះ ទៅសាធារណជន ក្នុងពេលឆាប់ៗនេះ។
- ដោយសារការផ្គត់ផ្គង់វ៉ាក់សាំងមានកំរិត ការចាក់វ៉ាក់សាំងនឹងធ្វើឡើងតាមដំណាក់កាល ហើយយើងផ្តល់អាទិភាពទៅអ្នកដែលចាំបាច់ត្រូវការវាមុន។









# អ្នកណាខ្លះនឹងបានចាក់វ៉ាក់សាំងកូវីដ-១៩?



unicef

World Health Organization
Representative Office for Cambodia



## តើអ្នកណាខ្លះមានអាទិភាពចម្បងក្នុងការចាក់វ៉ាក់សាំងកូវីដ-១៩?

យោងតាមអនុសាសន៍របស់អង្គការសុខភាពពិភពលោក ដោយបរិមាណនៃវ៉ាក់សាំងកូវីដ-១៩ មានកំណត់ និងតាមស្ថានភាពរបស់ប្រទេសកម្ពុជា រាជរដ្ឋាភិបាលបានសម្រេចឱ្យអាទិភាពទៅ៖



**ក្រុមអាទិភាពទី១**

- បុគ្គលិកសុខាភិបាល
- យោធា
- នគរបាលជួរមុខ
- មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល

**ក្រុមអាទិភាពទី២**

- ជនបង្គោលសហគមន៍
- ក្រុមទ្រទ្រង់សុខភាពភូមិ
- មនុស្សចាស់
- មនុស្សពេញវ័យដែលមានជំងឺប្រចាំកាយ

ប្រសិនបើអ្នកមិនស្ថិតក្នុងក្រុមនេះទេ អ្នកគួរអត់ធ្មត់រង់ចាំចាក់វ៉ាក់សាំង ដោយសារការផ្គត់ផ្គង់វ៉ាក់សាំងមានកំណត់។




យើងមិនទាន់មានទិន្នន័យអំពីការចាក់វ៉ាក់សាំងដល់កុមារអាយុក្រោម១៦ឆ្នាំនៅឡើយទេ ហេតុដូច្នេះហើយយើងមិនទាន់ច្បាស់អំពីសុវត្ថិភាពនិងប្រសិទ្ធភាពរបស់វ៉ាក់សាំងនេះចំពោះពួកគេនោះទេ។ ក្រសួងសុខាភិបាលនឹងធ្វើបច្ចុប្បន្នភាពនៅពេលដែលមានភ័ស្តុតាងអំពីប្រសិទ្ធភាព និងសុវត្ថិភាពរបស់វ៉ាក់សាំងកូវីដ-១៩ សម្រាប់កុមារអាយុក្រោម ១៦ឆ្នាំ។ វ៉ាក់សាំងខ្លះ ត្រូវបានណែនាំឱ្យចាក់សម្រាប់មនុស្សពេញវ័យដែលមានអាយុពី ១៨ឆ្នាំ។ ប្រសិនបើអ្នក ឬសមាជិកគ្រួសារអ្នកអាយុ ១៦ ឬ ១៧ឆ្នាំ សូមពិភាក្សាជាមួយ អ្នកផ្តល់សេវា មុននឹងចាក់វ៉ាក់សាំង។




អ្នកគួរតែចាក់វ៉ាក់សាំង ប្រសិនបើអ្នកស្ថិតក្នុងក្រុមអាទិភាពណាមួយ ទោះបីជាអ្នកមិនឃើញមានមនុស្សទៅចាក់ច្រើនក៏ដោយ។



## តើស្ត្រីបំបៅដោះកូនបានចាក់វ៉ាក់សាំងដែរ ឬ ទេ?

ពិតជាបាន។ អង្គការសុខភាពពិភពលោកណែនាំដល់ស្ត្រីបំបៅដោះកូនឱ្យចាក់វ៉ាក់សាំងកូវីដ-១៩ ក៏ដូចជាក្រុមទ្រទ្រង់សុខភាពភូមិ ឬ ក្រុមអាទិភាពណាមួយ ដែលតម្រូវឱ្យចាក់វ៉ាក់សាំងកូវីដ-១៩។



ការបំបៅកូនដោយទឹកដោះម្តាយមានសារសំខាន់ណាស់សម្រាប់ទារក និងម្តាយរបស់ពួកគេ។ អង្គការសុខភាពពិភពលោកបានណែនាំម្តាយឱ្យនៅតែបន្តបំបៅកូនដោយទឹកដោះ បន្ទាប់ពីចាក់វ៉ាក់សាំងរួច។